# សុខ និង ទុក្ខ

បទពំនោល

សុខនឹងទុក្ខនៅក្នុងចិត្ត ជាលោកិយក្រឹត្យ[1]
វាខិតខាំង[2]ផ្លូវជីវិត។
ដូច្នេះត្រូវចេះដង្វិន[3] ដ្បិតវាទាក់ទិន
នូវវិន[4]ជាប្រក្រតី។
ជួបសុខនាំចិត្តរីករាយ តែកុំរាយមាយ
នាំក្លាយជាវេទនា។
ជួបទុក្ខកុំថាកម្មពារ ដ្បិតជម៌ទាមទារ
អន្តរាយមានពីអតីត។
តែសុខទុក្ខជាបច្ចុប្បន្ន គ្មានការបន់ស្រន់
កំណត់ចែកខណ្ឌសីមា។
អំពើចេញពីចិន្តា វាជាតណ្ហា
បណ្ដាលហេតុដោយខ្លួនឯង។

---

[1] ក្រឹត្យ : ន. ច្បាប់។
[2] ខិតខាំង : កិ. ដាក់កំហិត។
[3] ដង្វិន : កិ. ត្រិះរិះ, ជញ្ជឹង។
[4] វិន ឬ វិន្ទ : ន. ការប្រទះ, ការជួប។ Rencontre.